អានិសង្សនៃការនៅទៀបគល់ឈើ

កាលនៅទៀបគល់ឈើ ជាសេចក្តីប្រតិបត្តិដ៏សមគួរដល់និស្ស័យ ព្រោះព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា៖

រុក្ខមូលសេនាសនំនិស្សាយបព្វជ្ជា អ្នកបួសត្រូវអាស្រ័យនៅទៀបគល់ឈើជាសេនាសន:។ មួយវិញទៀត ភិក្ខុអ្នកទ្រទ្រង់រុក្ខមូលិកធុតង្ត ជាហេតុឲ្យព្រះដ៏មានបុណ្យជាម្ចាស់ត្រាស់សរសើរថា បច្ច័យនឹងកើតដល់ភិក្ខុនោះតិច តែបច្ច័យនោះបានដោយងាយ ឥតមានទោសជាទំនងឲ្យកើតអប្បិច្ឆតាគុណ។

មិនតែប៉ុណ្ណោះ អនិច្ចសញ្ញានឹងកើតឡើងដល់ព្រះយោគាវចរភិក្ខុនោះ ព្រោះហេតុប្រទះនូវវិការ: នៃដើមឈើរឿយៗ នឹងប្រាសចាកសេចក្តីកំណាញ់ក្នុងសេនាសន: ប្រាសចាកសេចក្តីត្រេកអរក្នុងនវកម្ម (ការងារថ្មី) ជាមួយនឹងរុក្ខទេវតាហើយប្រព្រឹត្តទៅតាមគុណទាំងឡាយមានអប្បិច្ឆតាគុណជាប្រមាណ។

ព្រោះហេតុនោះបានជាព្រះពុទ្ធយោសាចារ្យលោកនិពន្ធគាថា សរសើរអានិសង្សនៃភិក្ខុអ្នកកាន់រុក្ខមូលិកធុតង្តថា៖ សេចក្តីថា លំនៅនៃបុគ្គលអ្នកស្ងាត់ ព្រះសម្មាសម្ពុទ្ធទ្រង់ពោលសរសើរថាជាទីសមគួរដល់និស្ស័យ, បណ្តាទីស្ងាត់រកទីណាឲ្យស្មើនឹងរុក្ខមូលនេះគ្មាន, ភិក្ខុដែលទ្រទ្រង់រុក្ខមូលិកធុតង្តជាប្រក្រតី រមែងនាំបង់នូវអាវាសមច្ឆរិយ: (សេចក្តីកំណាត់ក្នុងអាវាស) បាន ធម្មតាភិក្ខុដែលមានវត្តប្រតិបត្តិល្អ កាលបើនៅក្នុងទីស្ងាត់ គឺរុក្ខមូលដែលទេវតារក្សាហើយ បានទស្សនាការឃើញដើមឈើមានស្លឹកខៀវខ្ចី និងទុំក្រហមដែលជ្រុះចាកទងរមែងបន្ទោបង់នូវនិច្ចសញ្ញា (សេចក្តីសំគាល់ថាទៀង) ចេញបាន ព្រោះហេតុនោះបានជា ភិក្ខុដែលប្រកបដោយវិចារណប្បញ្ញាត្រេកអរក្នុងការភាវនា មិនត្រូវមើលងាយរុក្ខមូលសេនាសន:ដ៏ស្ងាត់ដែលជាទ្រព្យមត៌ករបស់ព្រះអរហន្តសម្មាសម្ពុទ្ធគ្រូ ទ្រង់ប្រទានទុកឲ្យនេះឡើយ។

ព្រោះការនៅអាស្រ័យក្នុងទីសេនាសន:ដ៏ស្ងាត់ទាំងឡាយមាន រុក្ខមូលជាដើម ជាទីប្រកបដោយប្រយោជន៍ច្រើនដូចពណ៌នាមកនេះ បានជាមានក្នុងអនុសាសនវិធី (ដែលធ្លាប់ហៅថាផ្តាំនាគ) ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់បង្គាប់ឲ្យភិក្ខុប្រៀនប្រដៅភិក្ខុបួសថ្មីក្នុងវេលាចប់ញត្តិចតុត្ថវាចាថ្មីៗ ថា៖

អ្នកបួសត្រូវអាស្រ័យនៅទៀបគល់ឈើជាសេនាសន: (ទីដេកទីអង្គុយ) , សេចក្តីព្យាយាមក្នុងការអាស្រ័យនៅដោយរុក្ខមូលសេនាសន:នោះអ្នកគប្បីធ្វើដរាបដល់អស់ជីវិត ដូច្នេះ។

រុក្ខមូលសេនាសន: រមែងជាទីអភិរម្យរបស់ព្រះយោគីអ្នកប្រាថ្នាសេចក្តីស្ងប់រម្ងាប់ជាធម្មតា, ព្រោះហេតុនេះបានជា ព្រះសម្ពុទ្ធជាបរមសាស្តារបស់យើង ទ្រង់ប្រសូតក្នុងលុម្ពិនីវនឱទ្យាន, ទ្រង់ត្រាស់អនុត្តរសម្ពោធិញាណនារុក្ខមូល គឺទៀបគល់ពោធិព្រឹក្ស ទ្រង់រំលក់ខន្ធបរិនិព្វានក្នុងសាលវនោទ្យានក្រោមលង្វែកមែករាំងទាំងគូរ។ ទីដែលព្រះបរមគ្រូទ្រង់ប្រសូត, ទ្រង់ត្រាស់ដឹង, ទ្រង់បរិនិព្វានសុទ្ធតែក្នុងព្រៃជាសេនាសន:ដ៏ស្ងាត់ទាំងអស់។

ការអាស្រ័យសេនាសនៈដ៏ស្ងាត់ដូច្នោះ ហើយព្យាយាមចម្រើនសមណធម៌ ក៏ជាឧបការៈ ឲ្យបន្ទោបង់សេចក្តីប្រមាទបាន។ ព្រោះហេតុនោះ បានជាព្រះយោគីអ្នកប្រាថ្នាសេចក្តីស្ងប់ ច្រើនតែគាប់ចិត្តអាស្រ័យនៅក្នុងព្រៃជាទីស្ងាត់ គួរដល់កាយវិវេក (សេចក្តីស្ងាត់កាយ) ដែលជាបច្ច័យឲ្យកើតចិត្តវិវេក (សេចក្តីស្ងាត់ចិត្ត) និងឧបធិវិវេក (សេចក្តីស្ងាត់ចាកកិលេស) ដូច្នេះហើយ, បើនៅព្រៃ កុំគ្រាន់តែស្ងាត់កាយប៉ុណ្ណោះ គួរឲ្យស្ងាត់ទាំងចិត្តនិងកិលេសផង ទើបឃើញថាការនៅក្នុងព្រៃសម្រេចប្រយោជន៍ល្អមែន ដូចភិក្ខុ ១ រូបដែលទៅចម្រើនសមណធម៌ក្នុងព្រៃស្ងាត់ ទោះបីឃើញវិសភាគារម្មណ៍ ក៏លោកខំសង្រួមចម្រើនសមណធម៌ដរាបដល់បានសម្រេចព្រះអរហត្តក្នុងទីនោះឯង។ សូមនាំរឿងនោះមកសំដែងជាឧទាហរណ៍ដូចតទៅនេះ៖

រឿងភិក្ខុមួយរូបចម្រើនធម៌ក្នុងព្រៃ

ភិក្ខុ ១ រូបកំពុងអង្គុយចម្រើនធម៌ក្នុងព្រៃ, គ្រានោះ មានស្ត្រីម្នាក់មត់នឹងបុរសម្នាក់ថានឹងមកជួបគ្នាក្នុងទីនោះ កាលបុរសនោះមិនមក, ស្ត្រីនោះក៏ធ្វើកលមាយាប៉ងនឹងធ្វើឲ្យភិក្ខុនោះខូចសីល តែលោកមានសតិសម្បជញ្ញៈល្អ ក៏នឹកសង្វេគខំធ្មេចភ្នែកច្រើនធម៌ មិនរំភើបឡើយ។ វេលានោះ ព្រះបរមគ្រូទ្រង់គង់ក្នុងគន្ធកុដិ ទ្រង់ផ្សាយព្រះរស្មីទៅប្រោសប្រាណដូចជាទ្រង់ប្រថាប់ក្នុងទីចំពោះមុខភិក្ខុនោះ ហើយត្រាស់ថា៖

រមណីយានិ អរញ្ញានិ យត្ថ ន រមតិ ជនោ
វីតរាគា រមេស្សន្តិ ន តេ កាមគវេសិនោ ។

សេចក្តី បណ្ឌិតទាំងឡាយជាអ្នកប្រាសចាករាគៈ មិនស្វែងរកកាម រមែងត្រេកអរក្នុងព្រៃជាទីគួររីករាយ ដែលមិនជាទីត្រេកអររបស់មហាជន។

នាំរឿងនេះមក ដើម្បីបញ្ជាក់សេចក្តីឲ្យឃើញច្បាស់ថាព្រះយោគាវចរដែលនៅអាស្រ័យក្នុងទីសេនាសនៈដ៏ស្ងាត់ គប្បីជាអ្នកស្ងាត់កាយស្ងាត់ចិត្ត និងស្ងាត់ទាំងកិលេសផង ទើបឈ្មោះថា បានសម្រេចប្រយោជន៍តាមអរិយប្បវេណី។ បើកាយនៅក្នុងព្រៃ តែចិត្តត្រេចទៅស្វែងរកកាមឯក្នុងស្រុក ក៏មិនសម្រេចប្រយោជន៍។

ព្រោះហេតុនោះ ព្រះយោគាចវរគប្បីបង្អោនចិត្តគិតរំពឹងតាមន័យដែលព្រះបរមសាស្តាចារ្យរបស់យើង កាលដែលទ្រង់កំពុងធ្វើទុក្ករកិរិយានៅឡើយ ទ្រង់រំពឹងឃើញច្បាស់ដោយសេចក្តីឧបមា ៣ យ៉ាងនោះចុះ។

ជកស្រែដ៏ចេញពីសៀវភៅ ឱ្យឧចាតិមោក្ខ